# សក្ខីកម្មរបស់ជនជាប់ចោទ : នួន ជា និង ខៀវ សំផន ឡើងនិយាយ ចំណែក អៀង សារី នៅតែស្ងៀមដដែល

**ដោយ ត្រីស៊ីន អ៊ីវេន**

**ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១**

*ប្រែសម្រួលដោយ ជា ផល្លា*

សវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តកិច្ចដំណើរការរបស់ខ្លួនទៀតនៅថ្ងៃនេះ ដោយផ្តោតការសាកសួរតែទៅលើជនជាប់ចោទប៉ុណ្ណោះ ។ ទោះបីជាជនជាប់ចោទ នួន ជា បានចំណាយពេលនិយាយពេញមួយព្រឹកក៏ដោយ ក៏ជនជាប់ចោទផ្សេងទៀតមានឱកាសឡើងនិយាយនៅពេលរសៀលដែរ ។ ខៀវ សំផន និង អៀង សារី មិនបានឆ្លើយសំណួរទៅនឹងការចោទសួរទេ តែ ខៀវ សំផន បានឆ្លើយតប ដោយអានសេចក្តីថ្លែងការណ៍របស់គាត់ដើម្បីឆ្លើយតបនឹងអ្វីដែលបានសរសេរនៅក្នុងដីកាដំណោះស្រាយ ។

ដោយសារតែការយឺតយ៉ាវតាំងពីសប្តាហ៍មុនមកម្ល៉េះ នៅថ្ងៃនេះ ចៅក្រម និល ណុន បានបង្គាប់ឲ្យចាប់ផ្តើមសវនាការនៅម៉ោងប្រាំបួនគត់ ។ ចៅក្រម និល ណុន បានជូនដំណឹងទៅគ្រប់ភាគីទាំងអស់និងសាធារណជន ដែលមាននិស្សិតនិងអ្នកភូមិថា សុខភាពរបស់សាក្សី ឡុង នរិន្ទ មិនទាន់ល្អប្រសើរនៅឡើយទេ ដូច្នេះអង្គសវនាការសម្រេចថានឹងចាប់ដំណើការសាកសួរជនជាប់ចោទ នួន ជា នៅព្រឹកនេះ ។ ខុសពីថ្ងៃមុនៗ ថ្ងៃនេះមិនមានបញ្ហាបឋមច្រើនត្រូវបានលើកមកនិយាយនៅក្នុងអង្គសវនាការទេ ដូច្នេះអនុរក្សមន្ទីរឃុំឃាំងបាននាំជនជាប់ចោទ នួន ជា មកកាន់ឈើរាំងរង់ក្រចកសេះ ។ ភ្លាមនោះ នួន ជា បានជូនដំណឹងទៅតុលាការថា ទោះបីជាគាត់បានសម្រាកពេញមួយសប្តាហ៍មកហើយក៏ដោយ តែគាត់មិនទាន់មានសុខភាពល្អនៅឡើយទេនៅពេលនេះ ។ តែគាត់បានបញ្ជាក់ថា គាត់អាចសហការជាមួយអង្គសវនាការឲ្យអស់ពីសមត្ថភាព ហើយបើសិនជាគាត់មិនសូវស្រួលខ្លួន គាត់នឹងសុំសម្រាក ។ ចៅក្រម និល ណុន បានឆ្លើយតបទៅ នួន ជា ថា គាត់នឹងត្រូវសាកសួរតែនៅពេលព្រឹកប៉ុណ្ណោះដោយសារតែបញ្ហាសុខភាព ហើយថា អង្គសវនាការនឹងកោះហៅជនជាប់ចោទ អៀង សារី និង ខៀវ សំផន មកចោទសួរនៅពេលរសៀល ។ ក្រោយមក ចៅក្រមបានបញ្ជាក់ថា អង្គសវនាការបានបញ្ជាក់ពីផលវិបាកក្នុងការនាំជនជាប់ចោទពីកៅអីមករង់ក្រចកសេះ ដោយចៅក្រមបានជម្រាបទៅសន្តិសុខឲ្យប្រើកៅអីរុញវិញ ដើម្បីឲ្យមានការងាយស្រួលជាង ។

## ***ចៅក្រម ខាតវ្រ៉ាយត៍ បានបន្តសាកសួរ នួន ជា***

*ចៅក្រម ខាតវ្រ៉ាយត៍ ត្រូវបានជូនឱកាសដើម្បីសាកសួរទៅ នួន ជា តែការចោទសួរនេះត្រូវបានពន្យារពេលតាំងពីថ្ងៃអង្គារទី៦ ខែធ្នូ មកម៉្លេះ ដោយសារតែពេលនោះអង្គសវនាការចង់ចោទសួរជនជាប់ចោទ ឡុង នរិន្ទ វិញ ។*

*ចៅក្រម ខាតវ្រ៉ាយត៍ បានចោទសួរ នួន ជា អំពីការអភិវឌ្ឍនៃមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ភ្លាមនោះដែរ ចៅក្រម ខាតវ្រ៉ាយត៍ បានសង្ខេបឡើងវិញនូវអ្វីដែល នួន ជា បានបកស្រាយកាលពីលើកមុនទាក់ទងទៅនឹងអ្វីដែលគាត់ហើយនិង ប៉ុល ពត បានសិក្សាពីស្ថានភាពប្រទេសក្នុងរវាងឆ្នាំ១៩៥៥ និង១៩៥៩ ហើយការសម្រេចចិត្តរបស់អ្នកទាំងពីរដែលបានអះអាងថាការធ្វើបដិវត្តន៍ជាតិពិតជាការចាំបាច់ណាស់ ។ ក្រោយមកចៅក្រម ខាតវ្រ៉ាយត៍ បានសួរទៅ នួន ជា ដើម្បីឲ្យគាត់បញ្ជាក់ឲ្យច្បាស់អំពីមាគ៌ានយោបាយ និងយុទ្ធសាស្ត្រដែលបាននិយាយនៅក្នុងកិច្ចប្រជុំបក្សក្នុងខែកញ្ញា ឆ្នាំ១៩៦០ ។ នួន ជា បានឆ្លើយថា គាត់ចង់បញ្ជាក់នូវអ្វីដែលចៅក្រម ខាតវ្រ៉ាយត៍ បាននិយាយ ។ ពេលនោះ នួន ជា បានបញ្ជាក់ថា គោលបំណងនៃបដិវត្តន៍មានពីរធំៗគឺ ទីមួយដើម្បីរំដោះជាតិ ដោយលុបបំបាត់ចោលនូវវត្តមានរបស់របបអាណានិគមនិយមនៅក្នុងប្រទេសនៅពេលនោះ និងទីពីរគឺដើម្បីរំដោះប្រជាជន ដែលមានន័យថា លុបបំបាត់ចោលរបបសក្តិភូមិ និងលើកកម្ពស់ស្ថានភាពរស់នៅរបស់ប្រជាជនកសិករ ដោយបញ្ចុះតម្លៃដី និងថ្លៃចងការខ្ពស់ ដើម្បីឲ្យប្រជាជនមានបាយហូបគ្រប់គ្រាន់ ។*

*ចៅក្រម ខាតវ្រ៉ាយត៍ បានសួរសំណួរទៀតថា តើមាគ៌ានយោបាយត្រូវបានពិភាក្សានៅកិច្ចប្រជុំបក្សក្នុងឆ្នាំ១៩៦០ឬទេ? នួន ជា បានពន្យល់ថា បក្សបានប្រមូលព័ត៌មាន និងសំណូមពរផ្សេងៗពីមូលដ្ឋានឡើងមកលើ ហើយក្រោយពីប្រមូលព័ត៌មានអស់ហើយ ទើបយកមកពិភាក្សាពីគោលនយោបាយនៅក្នុងអង្គប្រជុំ ។ ទាក់ទងទៅនឹងបដិវត្តន៍ប្រដាប់អាវុធដែលបានលើកមកនិយាយកាលពីសប្តាហ៍មុនខ្លះ ហើយចៅក្រម ខាតវ្រ៉ាយត៍ បានសួរទៅ នួន ជា ទៀតថា ផែនការបក្សក្នុងការធ្វើបដិវត្តន៍ តើបដិវត្តន៍នោះត្រូវមានការតស៊ូដោយអាវុធឬយ៉ាងណា ។ នួន ជា បានឆ្លើយថា «ពេលដំបូង គឺជាដំណាក់កាលតស៊ូនយោបាយ ។ កាលនោះមិនទាន់មានការតស៊ូដោយអាវុធទេ ។ ការតស៊ូដោយអាវុធទើបតែចាប់ផ្តើមនៅឆ្នាំ១៩៦៨ប៉ុណ្ណោះ បើខ្ញុំមិនច្រឡំទេ» ។ ដោយហៅអំឡុងពេលពីឆ្នាំ១៩៦៩ដល់ឆ្នាំ១៩៦៧ ថាជា«អំឡុងពេលនៃបដិវត្តន៍ប្រជាធិបតេយ្យ» នួន ជា បានពន្យល់ថាបដិវត្តន៍ប្រជាជនវាយតែរបបអាណានិគម និងសក្តិភូមិតាមវិធីសាស្ត្រនយោបាយតែប៉ុណ្ណោះ ។*

ដោយអានទស្សនាវដ្តីទង់បដិវត្តន៍ចុះផ្សាយថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៥ ចៅក្រម ខាតព្រាំយត៌ បាននិយាយអំពីអត្ថបទមួយ«យ៉ាងវែង» ទាក់ទងនឹងប្រវត្តិបដិវត្តន៍នៃការតស៊ូអាវុធនៅកម្ពុជា ដែលអត្ថបទនោះបានរៀបរាប់ថា ក្រោយពីកិច្ចប្រជុំឆ្នាំ១៩៦០ កម្មាភិបាលមកពីកន្លែងផ្សេងៗបានបង្កើតចលនាប្រដាប់អាវុធ ដោយពឹកផ្អែកលើមាគ៌ាយុទ្ធសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជា ហើយថាកងប្រដាប់អាវុធនោះមានឈ្មោះច្រើនណាស់ រួមមាន«អង្គភាពការពារសម្ងាត់»ផងដែរ ។ ពេលសួរថាមានចាំអំពីការពិភាក្សានោះទេ នួន ជា បានស្នើទៅចៅក្រម ខាតព្រាំយត៌ ឲ្យសួរសំណួរឡើងវិញម្តងទៀតឲ្យខ្លីបន្តិច ដោយសួរម្តងមួយៗដើម្បីឲ្យគាត់អាចឆ្លើយបានត្រឹមត្រូវ ។

ក្រោយពីសួរម្តងទៀតថា តើបដិវត្តន៍តស៊ូប្រដាប់អាវុធកម្ពុជាដើមឡើយជាអង្គភាពការពារសម្ងាត់ឬយ៉ាងណា នួន ជា បានបញ្ជាក់ថា កាលពីដំបូង បដិវត្តន៍គឺត្រឹមតែជាការតស៊ូនយោបាយប៉ុណ្ណោះ ។ នួន ជា បានបន្តទៀតថា អង្គភាពការពារសម្ងាត់នោះគឺដើម្បីការពារប្រជាជនពីការធ្វើបាបដោយកងនគរបាល និងដើម្បីជូនដំណើរកម្មាភិបាលពេលធ្វើដំណើរទៅកន្លែងណាមួយ ។ កងអង្គភាពនោះជ្រើសរើសចេញពីកូនចៅកសិករក្រីក្រ ហើយកងអង្គភាពនោះមិនមានកាន់អាវុធទេ អង្គភាពនោះមានត្រឹមតែ «ដំបង កាំបិត ពូថៅ» ប៉ុណ្ណោះ ។ ពេលសួរថាតើកងសម្ងាត់នោះមាននាទី«កម្ទេចខ្មាំង» ដូចបានបញ្ជាក់នៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ដែរឬទេ នួន ជា បានឆ្លើយថា ភារកិច្ចរបស់អង្គភាពនោះគឺដើម្បី«ការពារកម្មាភិបាល»មិនមែនដើម្បីសម្លាប់ និងកម្ទេចខ្មាំងទេ ។ គាត់បានបញ្ជាក់ទៀតថា ក្នុងករណីចាំបាច់ដូចជា ពេលដែលកម្មាភិបាលត្រូវបានវាយប្រហារពីកងនគរបាល និងត្រូវចាប់ឃុំឃាំង កងសម្ងាត់នេះ អាចប្រើប្រាស់អាវុធដើម្បីការពារខ្លួន និងដើម្បីការពារកម្មាភិបាល«ឲ្យអស់ពីសមត្ថភាព» ។ ទាក់ទងនឹងអ្វីដែលបានរៀបរាប់នៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍អំពី«ការកម្ទេចខ្មាំង» នួន ជា បានពន្យល់ថា កងសម្ងាត់នេះមិនស្វែងរកគិញដើម្បីកម្ទេចទេ ។ បើសិនជាមានខ្មាំងនៅក្នុងបក្សបង្កប់ខ្លួនដើម្បីចាប់កម្មាភិបាល កងសម្ងាត់នេះអាច«មានសិទ្ធិកម្ទេច»គិញទាំងនោះបាន ។

ចៅក្រម ខាតព្រាំយត៌ បាននិយាយសាឡើងវិញពីថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា ។ ដោយសម្អាងទៅលើមាត្រានៅក្នុងទង់បដិវត្តន៍ ចៅក្រម ខាតព្រាំយត៌ បានអានត្រង់កថាខណ្ឌមួយដែលនិយាយថា កងការពារសម្ងាត់នោះ«បាញ់កាំភ្លើងលើកទីមួយ»នៅក្នុងភូមិមួយជិតក្រុងបាត់ដំបង នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ ។ ពេលសួរថាតើនេះជាការបញ្ជារបស់គាត់ឬយ៉ាងណា នួន ជា មិនបានឆ្លើយសំណួរនេះទេ តែគាត់បានព្យាយាមផ្តល់ការពន្យល់ពីមូលហេតុដែលកងសម្ងាត់នេះនាំទៅរកការបះបោរដោយអាវុធក្នុងឆ្នាំ១៩៦៨ ។ នួន ជា បានអះអាងថា នៅពេលនោះ លន់ នល់ បានបញ្ជូនកងយោធារបស់ខ្លួន«រាប់រយរាប់ពាន់នាក់»ទៅខេត្តបាត់ដំបងដើម្បីចាប់ខ្លួន និងគាបសង្កត់អ្នកបះ

បោរ ហើយខ្លះទៀតត្រូវបានកាត់ក្បាលដោតនៅមុខផ្ទះ ។ នួន ជា បានបញ្ជាក់ថា “កងទ័ពដ៏សាហាវឃោរឃៅរបស់ លន់ នល់ សប្បាយរីករាយនឹងសម្លាប់ប្រជាជន” ។ ដើម្បីគេចពីការចាប់ខ្លួន និងសេចក្តីស្លាប់ អ្នកភូមិមកពីតំបន់នោះរត់ចូលព្រៃ តែគ្មានម្ហូបអាហារហូបចុកទេ ហើយការរស់នៅមានការលំបាកខ្លាំងណាស់ ។ សមាជិករបស់កងបះបោរទាំងនោះគឺចូលចលនានេះដោយស្ម័គ្រចិត្តដែលអ្នកទាំងនោះ គឺជាកូនចៅរបស់កសិករ ហើយចលនាបះបោរនេះបានវាយប្រហារប៉ុស្តិ៍ប៉ូលិសរបស់ លន់ នល់ និងរឹបអូសបានអាវុធជាច្រើន ដែលនេះហើយជាការចាប់ផ្តើមនៃការតស៊ូប្រដាប់អាវុធ ។ ចលនាតស៊ូនេះក៏បានរីករាលដាលទូទាំងប្រទេស ហើយក្នុងរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ ការបះបោររីករាលដាលដល់១៧ខេត្តក្នុងចំណោម១៩ខេត្តទូទាំងប្រទេស ។ នួន ជា បាននិយាយថា ប្រជាជន“មិនមានជម្រើសអ្វីទេ តែត្រូវតែងើបឡើងដើម្បីប្រឆាំង” ។ នៅពេលសួរថាតើគាត់បញ្ជាឲ្យមានការបះបោរដូចអ្វីដែលបានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ឬយ៉ាងណា នួន ជា បានបដិសេធដោយបញ្ជាក់ថាកាលនោះគាត់មិនរស់នៅក្នុងតំបន់បះបោរនោះទេ តែគាត់រស់នៅតាសាញ ហើយគាត់ក៏មិនដែលទទួលការបណ្តុះបណ្តាលខាងយោធាអ្វីដែរ ។

ចៅក្រម ខាតព្រ៉ាយត៍ បានសួរទៀតថា តើចលនាបះបោរមានឈ្មោះល្បីថាជាការកើតឡើងនៃបដិវត្តន៍ប្រដាប់អាវុធកម្ពុជាឬយ៉ាងណា នួន ជា បានឆ្លើយថា តាមគាត់ចាំ បដិវត្តន៍ប្រដាប់អាវុធកម្ពុជាចាប់កំណើតនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៦៨ ។ នួន ជា បាននិយាយទៀតថា វៀតណាមបានប្រាប់ថា បក្សកុម្មុយនីស្តកម្ពុជាមិនត្រូវតស៊ូប្រដាប់អាវុធទេ ព្រោះ“ជាការគ្រោះថ្នាក់ណាស់” ហើយបដិវត្តិន៍កម្ពុជានឹងមិនឈ្នះទេ ។ នួន ជា បន្តទៀតថា វៀតណាមតែងតែប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាជានិច្ច ហើយវៀតណាមមិនប្រគល់អាវុធឲ្យមកកម្ពុជាទេ ។

នួន ជា បាននិយាយទៀតថា បដិវត្តន៍ប្រដាប់អាវុធកម្ពុជាទទួលបានការឧបត្ថម្ភពីសមាជិកដែលមួយខែត្រូវឧបត្ថម្ភមួយរៀល ។ សមាជិករបស់បដិវត្តន៍ប្រដាប់អាវុធកម្ពុជានេះ គឺជា“កូនចៅកសិករ” ហើយសមាជិកនេះ ទទួលការឧបត្ថម្ភពីឪពុកម្តាយរបស់ខ្លួនដោយសារបដិវត្តន៍នេះមិនមានអាហារហូបចុកគ្រប់គ្រាន់ ។ អ្នកទាំងនោះតែងតែបាញ់សត្វព្រៃហូប ព្រោះកាលនោះសម្បូរសត្វព្រៃ ។ ពេលសួរថា តើគាត់ជួយឧបត្ថម្ភខ្លួនឯងយ៉ាងដូចម្តេច នួន ជា បានឆ្លើយថា “ខ្ញុំអត់មានអ្វីទេ ។ ខ្ញុំរស់នៅដោយសារប្រជាជនជួយ ។ ប្រជាជនទាំងនោះឲ្យអ្វីដែលខ្ញុំចង់បាន ។ ពេលដែលខ្ញុំនៅជាមួយគ្រួសារណា គ្រួសារនោះតែជួយលាក់ខ្ញុំជានិច្ច ហើយមិនប្រាប់គេថាខ្ញុំនៅទីនោះទេ” ។

នៅពេលសួរថាតើចលនាបះបោរនោះទទួលអាវុធមកពីណា នួន ជា ហាក់បីដូចជាមិនឆ្លើយសំណួរនេះទេ តែគាត់បានធ្វើការបន្ទោសវៀតណាមទៅវិញ ។ នួន ជា បានបញ្ជាក់ថា វៀតណាម

បាននិយាយថា ចង់ចែកអាវុធគ្នា តែ«វៀតណាមទុកទាំងអស់» ទោះបីជាវៀតណាមសុំដីខ្មែរនៅ និង ពឹងលើប្រជាជនកម្ពុជាដើម្បីចិញ្ចឹមជីវិតក៏ដោយ។ នួន ជា បាននិយាយថា គាត់និយាយនេះ គឺដើម្បី ឲ្យក្មេងជំនាន់ក្រោយដឹងថា «នរណាជំពាក់គុណនរណា»។ ត្រឡប់ទៅរកប្រធានបទទាក់ទងនឹងមាគ៌ា នយោបាយ និងយុទ្ធសាស្ត្រវិញ ចៅក្រម ខាតវ្រ៉ាយត៍ បានសួរទៅ នួន ជា ថាតើបក្សបាននិយាយ ពីការអភិវឌ្ឍរបស់បក្សក្នុងកិច្ចប្រជុំលក្ខន្តិកៈបក្សក្នុងឆ្នាំ១៩៦០ឬទេ? មុននឹង នួន ជា ឆ្លើយសំណួរ ចៅក្រម ខាតវ្រ៉ាយត៍ បានស្នើឲ្យមន្ត្រីតុលាការថតចម្លងឯកសារមួយសន្លឹកទៅ នួន ជា ហើយ ក្រោយមក ចៅក្រម ខាតវ្រ៉ាយត៍ បានស្នើទៅ នួន ជា បញ្ជាក់ឲ្យច្បាស់ពីលក្ខន្តិកៈរបស់បក្សមាន ៣០មាត្រាដែលគាត់បាននិយាយរួចហើយកាលពីសប្តាហ៍មុន។ នួន ជា បានបញ្ជាក់ថា លក្ខន្តិកៈនេះ មានតែ៣០ទំព័រប៉ុណ្ណោះ ហើយថានេះគឺជាលក្ខន្តិកៈដែលគាត់បាននិយាយកាលពីសប្តាហ៍មុន។

នៅពេលសួរថាហេតុអ្វីការបង្កើតបក្សកុម្មុយនីស្តកម្ពុជាមិនត្រូវបានប្រកាសរហូតដល់«ប្រមាណ ជា១៧ឆ្នាំក្រោយមក បន្ទាប់ពីបក្សនេះបានបង្កើតហើយនោះ» នួន ជា បានឆ្លើយថា «មិនមែនខ្ញុំម្នាក់ ឯងទេដែលត្រូវប្រកាសពីការបង្កើតជាផ្លូវការនេះ គឺវាអាស្រ័យទៅលើគណៈកម្មាធិការបក្ស»។ នួន ជា បានបញ្ជាក់ថា ហេតុផលដ៏សំខាន់ដែលមិនទាន់ប្រកាសអំពីការបង្កើតបក្សកុម្មុយនីស្តកម្ពុជានោះ គឺ ថា «នេះមាននៅកម្រិតតូចនៅឡើយ» ហើយបក្សនេះនៅតែរក្សាការអភិវឌ្ឍច្រើនឆ្នាំទៀត។ នួន ជា បានបញ្ជាក់ថា «ការប្រកាសជាសាធារណៈមិនបានផលអ្វីដល់បក្សទេ»។ គាត់បានបញ្ជាក់ទៀតថា ត្រូវ រង់ចាំរហូតដល់បក្សនេះទទួលការគាំទ្រពីសាធារណជន និងពីបរទេសជាមុនសិន។ នួន ជា បានបញ្ជាក់ ទៀតថា បក្សកុម្មុយនីស្តកម្ពុជាមានជំហរ និងទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តកម្ពុជា ហើយ«បក្ស ទទួលបានកេរ្តិ៍ឈ្មោះម្តងបន្តិចៗទូទាំងពិភពលោក»។

ចៅក្រម ខាតវ្រ៉ាយត៍ បានសួរថា តើនៅពេលណាទើបមានសេចក្តីសម្រេចជម្លៀសប្រជា ជនចេញពីទីក្រុងភ្នំពេញ។ នួន ជា បានឆ្លើយថា សេចក្តីសម្រេចចុងក្រោយដើម្បីជម្លៀសទីក្រុង ភ្នំពេញធ្វើឡើងក្នុងកិច្ចប្រជុំ«មិនពេញអង្គ»ជាច្រើនដងរបស់មជ្ឈិមបក្ស ចាប់តាំងពីឆ្នាំ១៩៧៣មក។ នួន ជា បានពន្យល់ថា ទីក្រុងភ្នំពេញត្រូវតែរំដោះមុនវៀតណាមរំដោះក្រុងព្រៃនគរ ហើយថា សេចក្តី សម្រេចក្នុងការវាយប្រហារផ្តាច់ព្រាត់ដើម្បីរំដោះទីក្រុងភ្នំពេញ គឺធ្វើឡើងក្នុងកិច្ចប្រជុំមួយកាលពីថ្ងៃ ទី១ ខែមករា ឆ្នាំ១៩៧៥។ ដើម្បីរៀបចំការវាយប្រហារនេះ គាត់និង ប៉ុល ពត បានទៅចរចា ជាមួយវៀតណាមដើម្បីសុំអាវុធពីវៀតណាមដែលចិនផ្តល់ឲ្យកម្ពុជា ដើម្បីយកមកវាយប្រហារយកទី ក្រុងភ្នំពេញ។ វៀតណាមបានប្រគល់ឲ្យកម្ពុជាចំនួន១៣ឡាន តែត្រូវបានបំផ្លាញដោយគ្រាប់បែករបស់

លន់ នល់ ទាំងអស់ ។ នួន ជា និយាយថា មានគិញរាយការណ៍ទៅ លន់ នល់ ដើម្បីមកទម្លាក់គ្រាប់បែក ។ នួន ជា បញ្ជាក់ថា «បដិវត្តន៍ប្រជាប់អាវុធកម្ពុជាតស៊ូរហូតទទួលបានជ័យជម្នះ» ។

នួន ជា បាននិយាយថាទៀតថា ស្ថានភាពនៅទីក្រុងភ្នំពេញគឺកាន់តែយ៉ាប់ទៅៗ ហើយប្រជាជនជួបប្រទះនូវការអត់ឃ្លានតាំងពីឆ្នាំ១៩៧២មក ហើយមិនមានអាហារបម្រុងទុកសម្រាប់ប្រជាជនធ្វើឲ្យការបះបោរពេញទីក្រុងភ្នំពេញទេ ។ លន់ នល់ មិនអាចគ្រប់គ្រងស្ថានការណ៍នោះបាន ហើយមនុស្សកាន់តែអត់មានអាហារហូបចុកច្រើនទៅៗ ។

ពេលពន្យល់ពីមូលហេតុដែលគណៈកម្មាធិការមជ្ឈិមសម្រេចចិត្តជម្លៀសទីក្រុងភ្នំពេញ នួន ជា បានពន្យល់ថា «ស្ថានភាពនៅទីក្រុងភ្នំពេញកាន់តែយ៉ាប់ទៅៗ» ដោយប្រជាជនអត់ឃ្លានយ៉ាងខ្លាំង ហើយការបះបោរមានកាន់តែច្រើនឡើងៗ ។ នួន ជា បានអះអាងថា «ប្រជាជនយើងនៅតំបន់រំដោះមានស្ថានភាពរស់នៅប្រសើរជាង ព្រោះយើងរស់នៅក្នុងសហករណ៍ ហើយអាចចែកគ្នាហូបបាន ។ ដូច្នេះ យើងត្រូវតែជម្លៀសប្រជាជនទៅនៅជនបទបណ្ដោះអាសន្នសិន ដើម្បីឲ្យអ្នកនោះមានរបស់ហូបចុកគ្រប់គ្រាន់» ។ ក្រោយមក នួន ជា បានពន្យល់ពីមូលហេតុដែលបានធ្វើការសម្រេចចិត្តអំពីទីកន្លែងដែលប្រជាជននោះត្រូវបញ្ជូនទៅ ហើយគាត់និយាយពី«ការរួមដៃគ្នា»របស់កសិករ និងប្រជាជនទាំងនោះត្រូវ«ប្រែក្លាយ»ទៅជាកសិករ ។ នួន ជា បានបញ្ជាក់ថា ប្រជាជនត្រូវធ្វើការ និងទទួលបានអាហារហូបចុកគ្រប់គ្រាន់ ដោយបីពេលក្នុងមួយថ្ងៃ ពេលព្រឹកហូបបបរ និងហូបបាយនៅពេលថ្ងៃ និងពេលល្ងាច ។ នួន ជា ក៏បានបញ្ជាក់ដែរថា ប្រជាជនត្រូវហូបបង្អែមម្ដងក្នុងមួយអាទិត្យ ។ ពេលដែលគាត់និយាយបែបនេះ ប្រជាជនដែលកំពុងត្រងត្រាប់ស្ដាប់ហាក់បីដូចជាមានអារម្មណ៍ខឹង ហើយនិយាយថា «មិនពិតទេ» ។ ក្រោយមក ដោយសារតែឃើញមានប្រតិកម្មពីប្រជាជន ដូច្នេះ នួន ជា បានអះអាងបញ្ជាក់ថា ការខ្វះខាតអាហារនៅតាមសហករណ៍គឺដោយសារ តែមាន«សមាសភាពមិនល្អ» នៅក្នុងជួរបក្ស ដែលអ្នកទាំងនោះមានបំណងបំផ្លាញសហករណ៍ ហើយថ្នាក់លើមិនដឹងពីអ្វីដែលបានកើតឡើងនៅសហករណ៍ទេ ។ នួន ជា បានបញ្ជាក់ទៀតថា «មនុស្សស្គមៗ»មិនត្រូវបានយកមកបង្ហាញឲ្យឃើញទេ ពេលដែលសមាជិកបក្សចុះទៅមូលដ្ឋានម្ដងៗ ហើយមានតែមនុស្សមានសាច់មានឈាមប៉ុណ្ណោះ ទើបយកមកឲ្យសមាជិកបក្សឃើញ ។ នួន ជា បាននិយាយទៀតថា ពេលដែលថ្នាក់ដឹកនាំទៅទស្សនាសហករណ៍ «សហករណ៍បានកាប់មាន់ចងព្យួរព្រោងព្រាត» ដើម្បីបន្លំភ្នែកថ្នាក់ដឹកនាំ ។ នួន ជា អះអាងថា ការដែលគាត់មិនដឹងពីរឿងរ៉ាវទាំងនោះ គឺដោយសារតែ«មានការកេងបន្លំនៅក្នុងសហករណ៍» ។

ក្រោយពី នួន ជា ឆ្លើយចប់អំពីការជម្លៀសប្រជាជន ចៅក្រម ខាតព្រ៉ាយត៍ បានបញ្ចប់សំណួររបស់គាត់ដែរ ហើយលោកស្រីចៅក្រមបានសុំឲ្យមានការដាក់បង្ហាញពីឯកសារមួយចំនួនទៅចំពោះមុខអង្គសវនាការមុននឹងដល់ម៉ោងសម្រាក ។ ចៅក្រម និល ណុន បានប្រកាសឲ្យសម្រាក ។

## ចៅក្រម ឡាវ៉ែរញ ចោទសួរ នួន ជា

ក្រោយពីសម្រាក ចៅក្រម និល ណុន បានប្រគល់តួនាទីនេះទៅឲ្យចៅក្រម ខាតព្រ៉ាយត៍ម្តងទៀតដើម្បីឲ្យគាត់ដាក់ឯកសារនៅចំពោះមុខតុលាការ ។ ចៅក្រម ខាតព្រ៉ាយត៍ បានប្រាប់លេខឯកសារទៅតុលាការអំពីទស្សនាវដ្តីទង់បដិវត្តន៍បីលេខ ។ ក្រោយមក ចៅក្រម ខាតព្រ៉ាយត៍ បាននិយាយថា ឯកសារត្រូវបានដាក់ជូនទៅតុលាការហើយ ។ ក្រោយមក ចៅក្រម និល ណុន បានសួរទៅចៅក្រម ខាតព្រ៉ាយត៍ ថាតើមានសំណួរអ្វីទៀតទេ ។ ដោយចៅក្រម ខាតព្រ៉ាយត៍ មិនមានសំណួរ ចៅក្រម ឡាវ៉ែរញ ចាប់ផ្តើមសួរទៅកាន់ នួន ជា តែគាត់បានបង្អាក់បន្តិចដោយសារបញ្ហាបកប្រែ ។ ពេលនោះមានការសម្រាកបន្តិច ។

ចៅក្រម ឡាវ៉ែរញ បានចាប់ផ្តើមសួរសំណួរទៅ នួន ជា ថាតើពាក្យព្រៃនគរដែលបាននិយាយនោះគឺដូចគ្នាទៅនឹងឈ្មោះទីក្រុងហូជីមិញដែរឬទេ ។ នួន ជា បានបញ្ជាក់ថាត្រឹមត្រូវ ហើយថាដោយសារទីនោះគឺជាអតីតទឹកដីរបស់ខ្មែរ ហើយទីក្រុងនោះមានឈ្មោះថាព្រៃនគរ ។ នួន ជា បានបញ្ជាក់ទៀតថា គាត់មិន“បង្កប់ន័យ”អ្វីទេក្នុងការប្រើប្រាស់ពាក្យនេះ ។

ចៅក្រម ឡាវ៉ែរញ បានរំឭកថា នួន ជា ធ្លាប់និយាយថា គាត់មានចិត្ត“មេត្តា”ចំពោះប្រជាជនដែលទទួលការគាបសង្កត់ពីពួកអាណានិគមនិយមបារាំង ។ ចៅក្រម ឡាវ៉ែរញ បានសួរទៅ នួន ជា ថា ពាក្យថា“មេត្តា”នោះមានជាប់ពាក់ព័ន្ធនឹងពុទ្ធសាសនាដែរឬទេ ។ នួន ជា បាននិយាយថា នេះពិតជាត្រឹមត្រូវ ហើយថា ព្រះពុទ្ធតម្រូវឲ្យមនុស្សមានចិត្តមេត្តាគ្នាទៅវិញទៅមក ។ ពេលសួរថាតើគោលការណ៍នេះជាប់ពាក់ព័ន្ធទៅនឹងការមិនប្រើហិង្សាដែរឬទេ នួន ជា បានឆ្លើយថា តាមគោលការណ៍បដិវត្តន៍ ត្រូវតែមានការវាយប្រហារដោយអាវុធ សូម្បីព្រះពុទ្ធសាសនាក៏ឲ្យមានការប្រើប្រាស់អាវុធដែរ ។ នួន ជា បាននិយាយទៀតថា “បើតាមគំនិតខ្ញុំ ទស្សនៈទាំងពីរនេះដើរស្របគ្នា” ។ ចៅក្រម ឡាវ៉ែរញ បានសួរទៅ នួន ជា ទៀតថា តើក្តីមេត្តានេះគួរតែកើតឡើងចំពោះជនរងគ្រោះដោយការជម្លៀស ការធ្វើជាទាសករ និងទម្រង់ផ្សេងទៀតនៃការការគាបសង្កត់ដែរឬទេ ។ នួន ជា បានឆ្លើយថា តាមគំនិតរបស់គាត់ បដិវត្តន៍តម្រូវឲ្យមានការលះបង់កម្លាំងកាយនិងកម្លាំងចិត្តដើម្បីកសាងប្រទេសជាតិ ចំណែកឯសាសនាតម្រូវឲ្យមានក្តីមេត្តា និងការសន្តោសដើម្បីកសាងប្រទេសជាតិ ។ នួន ជា និយាយថា “បើគ្មានការលះបង់កម្លាំងកាយទេ បដិវត្តន៍យើងក៏មិនអាចទទួលលទ្ធផលអ្វីដែរ” ។

នួន ជា បានបញ្ជាក់បន្ថែមទៀតថា «កុម្មុយនីស្តលុបបំបាត់តែប្រជាជនដែលចង់បំផ្លាញបក្ស និងប្រទេសតែប៉ុណ្ណោះ និងអ្នកណាដែលកែមិនឡើង» ហើយគាត់ក៏បានបញ្ជាក់ទៀតថា បក្សបានផ្តល់ឱកាសបីដងដើម្បីកែខ្លួន «បើសិននរណាម្នាក់មិនអាចកែខ្លួនបានទេ អ្នកនោះនឹងត្រូវដកចេញពីបក្ស» ។ បក្សមិនមានសិទ្ធិអំណាច«កម្ទេច»នរណាម្នាក់ទេ តែអ្នកដែលមិនត្រូវគ្នានឹងបក្សគឺត្រូវ«ដកចេញ»ពីបក្ស និងបញ្ជូនទៅមូលដ្ឋាន«ដើម្បីធ្វើពលកម្ម ។ ការដែលចោទថា អ្នកនោះត្រូវបានសម្លាប់ ឬប្រព្រឹត្តអំពើប្រល័យពូជសាសន៍បែបនេះគឺមិនពិតទេ» ។

នួន ជា បាននិយាយថា សង្គ្រាមមានពីរបែបគឺ «សង្គ្រាមឈ្លានពាន» និង«សង្គ្រាមរំដោះជាតិ» ។ គាត់និយាយទៀតថា សង្គ្រាមឈ្លានពានគឺប្រព្រឹត្តដោយអាមេរិកនិងវៀតណាម ។ ក្រោយមក ចៅក្រម ឡាវីញ សួរទៅ នួន ជា ថាតើពេលណាទើបបក្សចេញផែនការ«កម្ទេចមនុស្សសមាសភាពអាក្រក់» ។

ទោះបីជា នួន ជា ត្រូវបានប្រាប់ឲ្យឆ្លើយឲ្យចំសំណួរក៏ដោយ តែគាត់នៅតែឆ្លើយសំណួរមិនចំចំណុចដដែល ។ ជួសមកវិញ នួន ជា បាននិយាយថា «បដិវត្តន៍ត្រូវកសាងកម្លាំង មិនមែនកម្ទេចខ្មាំងទេ លើកលែងតែក្នុងករណីខ្លះមនុស្សមិនអាចអប់រំបាន ឬមិនអាចកែខ្លួនបាន ។ អ្នកនោះ គឺជាមនុស្សកាចសហាវ ហើយមិនអាចកែខ្លួនបាន» ។ នួន ជា បានបញ្ជាក់ទៀតថា អ្នកដែលមាន«សមាសភាពអាក្រក់»ដែលត្រូវកម្ទេចគឺជាខ្មាំង ឬគិញ ហើយអ្នកនោះមិនអាចកែខ្លួនបាន ។ នួន ជា និយាយថា «យើងត្រូវតែថែរក្សាធនធានមនុស្សដើម្បីកសាងប្រទេស ជាជាងសម្លាប់អ្នកនោះចោល» ។

ក្រោយពី ចៅក្រម ឡាវីញ សួរសំណួរម្តងទៀត នួន ជា បានឆ្លើយថា មាគ៌ានយោបាយបានអភិវឌ្ឍនៅពេលដែល«សង្គ្រាមវៀតណាមកាន់តែរាលដាលខ្លាំងទៅៗ» និងនៅពេលដែលអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែកមកលើកទឹកដីកម្ពុជា ។ នួន ជា បាននិយាយថា «ភាពខ្ទេចខ្ទាំនិងកំហឹងរបស់ប្រជាជនជំរុញឲ្យមានស្មារតីជាតិនិយម ។ ឲ្យយើងនៅស្ងៀមម្តេចនឹងបាននៅពេលដែលសត្រូវវាយប្រហារយើងហើយនោះ» ។

ក្រោយមក ចៅក្រម ឡាវីញ បានសួរឲ្យបែកឲ្យដាច់រវាង «ជម្លោះនយោបាយ» និង «បដិវត្តន៍ប្រដាប់អាវុធ» និងថាតើជម្លោះនយោយបាយនោះមានទម្រង់ហិង្សាដែរឬទេ ។ នួន ជា បានឆ្លើយថា គាត់មិនដែលបដិសេធថា ការតស៊ូដោយអាវុធមិនបានកើតឡើងនោះទេ តែ«ការតស៊ូដោយអាវុធនោះគឺមិនធ្វើតាមគោលការណ៍មូលដ្ឋានដែលយើងបង្កើតឡើងទេ ។ ជម្លោះនយោបាយនេះរួមមាន ការបះបោរប្រឆាំង កូដកម្ម និងការតវ៉ារួមគ្នា និង«ពួតដៃគ្នា»ក្នុងចំណោមកសិករ ។ នួន ជា ក៏បន្ថែមទៀតថា ការតស៊ូប្រដាប់អាវុធជារឿង«សំខាន់ណាស់» តែ «យើងមិនបោះបង់ចោលការតស៊ូ

ដោយនយោបាយទេ... ព្រោះប្រជាជនចូលចិត្តការតស៊ូនយោបាយនេះ... បើយើងចាញ់សមរភូមិនេះ វាជារឿងធម្មតាទេ តែបើចាញ់ការតស៊ូនយោបាយ នោះគឺជាបញ្ហាហើយ» ។

ដោយទុកសំណួរអំពីការតស៊ូប្រដាប់អាវុធមួយអន្លើ ចៅក្រម ឡាវ៉ែរ៉ាញ បានសួរ នួន ជា អំពីទំនាក់ទំនងរវាង«ចលនាកុម្មុយនីស្តថ្នាក់ទាប» ដែល នួន ជា នៅក្នុងក្រុមនោះដែរ និងក្រុមបញ្ញវន្តច្រើនដែលរួមមាន ខៀវ សំផន ជាដើម ។ នួន ជា បានឆ្លើយដោយមិនចំសំណួរទេ ហើយគាត់បានបញ្ជាក់ថា ប៉ុល ពត ប្រាប់គាត់ថាមិនត្រូវទាក់ទងជាមួយបញ្ញាជនទាំងនោះទេព្រោះគាត់មិនមែនជាបញ្ញវន្ត ។ នៅពេលសួរពីសំណួរនេះម្តងទៀត នួន ជា បានបញ្ជាក់ថា អ្នកដែលធ្លាប់ទៅរៀននៅប្រទេសបារាំង ដូចជា ប៉ុល ពត និង អៀង សារី ទើបអាចទាក់ទងជាមួយបញ្ញវន្តបាន ។ ចៅក្រម ឡាវ៉ែរ៉ាញ បានសួរទៅ នួន ជា ទៀតថា នៅពេលណាទៅគាត់ជួបជាមួយ ខៀវ សំផន និង អៀង សារី ។ នួន ជា បានឆ្លើយថា គាត់ទើបតែជួប ខៀវ សំផន ក្រោយពីរំដោះភ្នំពេញហើយទេ ។ ទោះបីជាក្រោយរំដោះភ្នំពេញហើយក៏ដោយ នួន ជា បានបញ្ជាក់ថា គាត់កម្រជួបជាមួយ ខៀវ សំផន ណាស់ ។ ចំពោះ អៀង សារី វិញ គាត់ធ្លាប់ជួបម្តងម្កាលព្រោះអ្នកទាំងពីរនេះគឺជាសមាជិកគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ។

ក្រោយពីអាហារថ្ងៃត្រង់ ប្រធានចៅក្រមសួរទៅ នួន ជា ថាតើគាត់អាចបន្តឆ្លើយសំណួរនៅពេលរសៀលនេះទៀតបានទេ ។ នួន ជា បានឆ្លើយថា គាត់នឹងព្យាយាមបន្តទៀតទោះជាគាត់ហត់នឿយក៏ដោយ តែគាត់បានស្នើឲ្យសួរសំណួរខ្លីនិងស្រួលយល់ ។ ម៉ៃឃើល ខាណាវ៉ាស ដែលជាមេធាវីរបស់ អៀង សារី បានស្នើទៅតុលាការដើម្បីឲ្យគ្រូពេទ្យមកពិនិត្យកូនក្តីរបស់គាត់ពេលអាហារថ្ងៃត្រង់នេះ ធ្វើដូច្នេះទើបគាត់អាចសម្រេចចិត្តបានសម្រាប់ពេលរសៀលនេះ ។ ចៅក្រម និល ណុន បានស្នើឲ្យគ្រូពេទ្យពិនិត្យសុខភាពជនជាប់ចោទ ហើយក្រោយមក ចៅក្រមបានបន្តាប់ឲ្យសម្រាកថ្ងៃត្រង់ ។

## អៀង សារី ទាមទារសិទ្ធិនៅស្ងៀម

បន្ទាប់ពីហូបអាហារថ្ងៃត្រង់ ក្នុងបន្ទប់សវនាការមិនសូវមានអ្នកចូលរួមទេ ព្រោះនិស្សិតដែលចូលព្រឹកមិញបានត្រឡប់ទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍អស់ហើយ តាមកម្មវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ពេលនេះមានអ្នកអង្គុយតែប្រាំជួរប៉ុណ្ណោះ ។ នៅពេលរសៀលនេះ អ្នកចូលរួមមានសភាពស្ងប់ស្ងាត់ និងមិនមានប្រតិកម្មអ្វីទេ ពេលស្តាប់សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទនោះ ។

ក្រោយមក ចៅក្រម និល ណុន បានចាប់ផ្តើមសវនាការនៅម៉ោង១១:៣០នាទី ហើយគាត់បានជម្រាបទៅគ្រប់ភាគីទាំងអស់ថា វេជ្ជបណ្ឌិតបានពិនិត្យសុខភាព នួន ជា រួចហើយ ហើយសុខភាពរបស់គាត់មិនមានអ្វីផ្លាស់ប្តូរជាដុំកំភួនទេ ហើយគាត់និយាយថា នួន ជា អាចបន្តធ្វើសក្ខីកម្មបន្តទៀតនៅពេលរសៀលនេះ។ នួន ជា បានប្រកាសថា គាត់អស់កម្លាំងនិងស្នើទៅតុលាការថា គាត់ចង់បន្តសក្ខីកម្មនៅព្រឹកស្អែកវិញ។ ក្រោយពីចៅក្រមទាំងអស់ពិភាក្សាគ្នារួចហើយ ចៅក្រមបានអនុញ្ញាតហើយភ្លាមនោះអង្គសវនាការបង្គាប់ឲ្យ អៀង សារី ចូលមកកាន់វង់ក្រចកសេះ។

អៀង សារី បាននិយាយពីសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមជាច្រើនលើកច្រើនសាមកហើយ តែពេលនេះមេធាវីរបស់ អៀង សារី មិនជំទាស់អ្វីទេពេលដែល អៀង សារី ត្រូវបាននាំទៅកាន់ទីក្រចកសេះ។ ក្រោយមក អៀង សារី បានឆ្លើយទៅនឹងសំណួរដែលសួរអំពីប្រវត្តិរូបសង្ខេបរបស់គាត់ដែលសួរដោយចៅក្រម និល ណុន។ អៀង សារី បានប្រាប់ឈ្មោះថ្ងៃខែឆ្នាំកំណើត និងគ្រួសារ។ នៅពេលដែលចៅក្រមចាប់ផ្តើមសួរអំពីកម្រិតវប្បធម៌របស់គាត់ មេធាវី ខារណាវ៉ាស បាននិយាយកាត់ និងបានរំឭកតុលាការអំពីអ្វីដែល អៀង សារី បានដាក់ជូនទៅតុលាការរួចហើយកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១កន្លងទៅ អំពីការរក្សាសិទ្ធិនៅស្ងៀមមិននិយាយអ្វីទាំងអស់។ មេធាវី ខារណាវ៉ាស បានជូនដំណឹងទៅតុលាការថា អៀង សារី ត្រៀមខ្លួនរួចជាស្រេចដើម្បីអានសេចក្តីថ្លែងការណ៍របស់គាត់ទាក់ទងនឹងបញ្ហានេះ «ព្រោះយើងរំពឹងថា តុលាការនឹងព្យាយាមសួរគាត់ទៀត»។

ចៅក្រម និល ណុន បានបញ្ជាក់ថា សំណួរដែលទាក់ទងទៅនឹងកម្រិតវប្បធម៌ គឺជាសំណួរទូទៅ «មិនមែនទាក់ទងទៅនឹងការសារភាពទេ»។ ក្រោយមក ចៅក្រម និល ណុន បានប្រាប់ពីសិទ្ធិរបស់ អៀង សារី។ ចៅក្រមបញ្ជាក់ថា អៀង សារី មានសិទ្ធិទទួលបានការការពារដោយមេធាវីរបស់ខ្លួនគ្រប់ពេលទាំងអស់។ ពេលនេះជនជាប់ចោទមានមេធាវីអន្តរជាតិម្នាក់ និងមេធាវីជាតិម្នាក់ ហើយមេធាវីនេះបានការពារតាំងពីអង្គបុរេជំនុំជម្រះមកម្ល៉េះ។ ចៅក្រមក៏បានប្រាប់ អៀង សារី អំពីសិទ្ធិក្នុងការនៅស្ងៀម សិទ្ធិក្នុងការមិនឆ្លើយដើម្បីដាក់ពិរុទ្ធមកលើខ្លួនឯង និងសិទ្ធិក្នុងការដឹងនូវអ្វីដែលបានចោទប្រកាន់មកលើខ្លួន។ នៅពេលសួរថាតើមានបានទទួលដំណឹងពីការចោទប្រកាន់មកលើខ្លួនទេ អៀង សារី បានឆ្លើយថាបាន។ ដូច្នេះ ចៅក្រមមិនបានអានបទចោទប្រកាន់ទៀតទេ។

ក្រោយមក ចៅក្រម និល ណុន បានសួរថាតើ អៀង សារី ចង់រក្សាសិទ្ធិនៅស្ងៀមដែរឬទេ។ អៀង សារី បានអានសេចក្តីថ្លែងការណ៍របស់គាត់ ហើយបានប្រាប់ទៅតុលាការថា គាត់មិនឆ្លើយសំណួរណាមួយទៅចៅក្រមទេ។ ចៅក្រម ឡាវ៉ើញ បានឲ្យ អៀង សារី បញ្ជាក់ឲ្យច្បាស់ម្តង

ទៀតថាតើគាត់«បដិសេធ» មិនធ្វើការបកស្រាយណាមួយទៅនឹងអ្វីដែលបានសរសេរក្នុងដីកាដំណោះស្រាយទេឬយ៉ាងណា ។

ម៉ៃ ឃើល ខាណាវ៉ាស ជំទាស់ទៅនឹងអ្វីដែលចៅក្រមប្រើពាក្យ«បដិសេធ»នេះដោយបញ្ជាក់ថា កូនក្តីរបស់គាត់មិនមែនបដិសេធមិនឆ្លើយសំណួរទេ តែកូនក្តីរបស់គាត់«សុំប្រើសិទ្ធិដែលបានចែងក្នុងរដ្ឋធម្មនុញ្ញដោយមិនឆ្លើយសំណួរអំឡុងពេលសវនាការនេះ» ។ ចៅក្រម ឡាវើញ បានឆ្លើយតបថា គាត់ចង់ដឹងច្បាស់ថាតើ អៀង សារី ចង់បញ្ចេញយោបល់ណាមួយទៅតុលាការ ។ អៀង សារី បានឆ្លើយម្តងទៀតថា គាត់មិនមានបំណងឆ្លើយសំណួរណាមួយទេ ។

## ខៀវ សំផន ឆ្លើយតបទៅនឹងដីកាដំណោះស្រាយ

ដោយសារតែ អៀង សារី សុំសិទ្ធិនៅស្ងៀមមិនឆ្លើយ ឬធ្វើសេចក្តីថ្លែងការណ៍នៅពេលនេះ ចៅក្រម និល ណុន បានបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន អៀង សារី ទៅអង្គុយពីក្រោយមេធាវីរបស់គាត់វិញ ។ ក្រោយពី អៀង សារី ដិះរទេះរុញទៅដល់ទីកន្លែងហើយ មេធាវីអន្តរជាតិរបស់ ខៀវ សំផន បានជម្រាបទៅតុលាការអំពីគោលបំណងកូនក្តីរបស់គាត់ក្នុងការឆ្លើយសំណួរពីតុលាការនិងភាគីផ្សេងទៀត ។

ដោយបញ្ជាក់ថា ខៀវ សំផន ក៏មានគម្រោងនឹងមិនឆ្លើយសំណួរដែរនោះ មេធាវីរបស់គាត់បាននិយាយថា ខៀវ សំផន សុំធ្វើសេចក្តីថ្លែងការណ៍វិញ ដើម្បីឆ្លើយតបទៅនឹងអ្វីដែលមាននៅក្នុងដីកាដំណោះស្រាយ ។ ក្រោយពីមេធាវីរបស់គាត់បញ្ចប់មតិរួចហើយ ខៀវ សំផន ត្រូវបាននាំចូលមកក្នុងទីក្រចកសេះ ។ ក្រោយពីឆ្លើយសំណួរអំពីប្រវត្តិរបស់ខ្លួនដែលសួរដោយចៅក្រមរួចហើយ ខៀវ សំផន ត្រូវបានសួរអំពីកម្រិតវប្បធម៌ ។ ខៀវ សំផន បានឆ្លើយថា ក្រោយពីបញ្ចប់បឋមសិក្សា និងអនុវិទ្យាល័យនៅស្រុកកំណើត គាត់បានប្តូរមកនៅភ្នំពេញដើម្បីរៀនថ្នាក់វិទ្យាល័យ ហើយគាត់រៀនចប់នៅឆ្នាំ១៩៥១ ។ ពីឆ្នាំ១៩៥១ដល់១៩៥៣ គាត់ធ្វើជាគ្រូបង្រៀនដើម្បីជួយផ្គត់ផ្គង់គ្រួសារពេលដែលគាត់កំពុងរៀនច្បាប់ ។ ទីបញ្ចប់ ក្នុងឆ្នាំ១៩៥៣ គាត់បានទៅប្រទេសបារាំងដើម្បីរៀនខាងច្បាប់ ហើយគាត់រៀនចប់នៅឆ្នាំ១៩៥៨ ហើយក៏បានត្រឡប់មកកាន់ប្រទេសកម្ពុជាភ្លាមដែរ ។

ក្រោយមក ចៅក្រមបានអានអំពីបទចោទប្រកាន់មកលើ ខៀវ សំផន ហើយចៅក្រមបានសួរទៅ ខៀវ សំផន ថាគាត់ចង់រក្សាសិទ្ធិនៅស្ងៀមដែរឬទេ ។ ជនជាប់ចោទ ខៀវ សំផន បានឆ្លើយថា គាត់មិនអាចឆ្លើយសំណួរនៅពេលនេះបានទេ តែគាត់ចង់ឆ្លើយទៅនឹងអ្វីដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយវិញ ។ ខៀវ សំផន បាននិយាយថា គាត់សម្រេចថាតើគាត់នឹងឆ្លើយសំណួរក្រោយពីព្រះរាជអាជ្ញាបញ្ចប់ការបង្ហាញភស្តុតាង ។

ក្រោយមក ចៅក្រមបានអនុញ្ញាតឲ្យ ខៀវ សំផន អានសេចក្តីថ្លែងការណ៍របស់គាត់ដើម្បីឆ្លើយតបទៅនឹងកថាខណ្ឌដាក់លាក់ណាមួយនៅក្នុងដីកាដំណោះស្រាយ ។ សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ គឺគ្របដណ្តប់រយៈពេលពីឆ្នាំ១៩៥១រហូតដល់១៩៧៥ ហើយគាត់បានបកស្រាយទៅនឹងសកម្មភាពមួយចំនួនដែល ខៀវ សំផន បានចូលរួម ដូចអ្វីដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ។ ខៀវ សំផន បានបញ្ជាក់ថា គាត់បានចាកចេញពីប្រទេសកម្ពុជាទៅប្រទេសបារាំងក្នុងឆ្នាំ១៩៥៣ ។ កាលនោះ ប៉ុល ពត បានចាកចេញពីប្រទេសបារាំងរួចទៅហើយ ដូច្នេះ ខៀវ សំផន មិនបានជួបជាមួយ ប៉ុល ពត ទេ តែគាត់បានជួប អៀង សារី ។ ក្នុងរយៈពេលពីរបីខែដំបូងនៅប្រទេសបារាំង មិត្តម្នាក់បានមកស្នើ ខៀវ សំផន ជាច្រើនលើកច្រើនសា ដើម្បីឲ្យគាត់ចូលក្នុង«វង់ម៉ាកស៊ីស» ។ ទីបញ្ចប់ ខៀវ សំផន សម្រេចចូលប្រជុំព្រោះគាត់«មិនចង់ឲ្យគេថា គាត់កំសាក» ។ មុននឹងគាត់កាន់តែមានភាពជិតស្និទ្ធជាមួយវង់ម៉ាកស៊ីសនោះ គាត់បានប្តូរទៅនៅក្រុងម៉ុងប៉េលីយេ ភាគខាងត្បូងប្រទេសបារាំងដើម្បីរៀនច្បាប់ និងពាណិជ្ជកម្ម ។ គាត់បានទៅទីក្រុងប៉ារីសវិញពេលវិស្សមកាលរដូវក្តៅ ។ ខៀវ សំផន បញ្ជាក់ថា ពេលនោះហើយទើបគាត់ដឹងច្រើនពីវង់ម៉ាកស៊ីស ។ បីឆ្នាំក្រោយមក ខៀវ សំផន បានត្រឡប់មកទីក្រុងប៉ារីសវិញ ដើម្បីបញ្ចប់សារណាផ្នែកសេដ្ឋកិច្ចរបស់គាត់នៅពេលនោះ គាត់ចាប់ផ្តើមចូលរួមប្រជុំជាមួយវង់ម៉ាកស៊ីសជាញឹកញាប់ ។

ខៀវ សំផន បានផ្លាស់ប្តូរប្រធានបទ ហើយពេលនេះគាត់បានពន្យល់ថា ប្រទេសកម្ពុជានឹងទទួលបានឯករាជ្យពីប្រទេសបារាំងឆាប់ៗ ។ អៀង សារី បានសម្រេចចិត្តត្រឡប់មកប្រទេសកម្ពុជាវិញ ហើយប្រគល់ការដឹកនាំនៃក្រុមនោះទៅឲ្យ ខៀវ សំផន កាន់ជំនួសវិញ ព្រោះគាត់«គ្មានជម្រើសណាផ្សេងទេ» ព្រោះសមាជិកសកម្មជាច្រើនបានត្រឡប់ទៅកាន់ប្រទេសកម្ពុជាអស់ហើយ ហើយមានមនុស្សម្នាក់«មានសង្សារច្រើន និងចូលចិត្តរាំតាមបែបបារាំង» ។

ទាក់ទងទៅនឹងការអភិវឌ្ឍមនោគមន៍វិជ្ជាពេលដែលគាត់នៅប្រទេសបារាំង ខៀវ សំផន បានពន្យល់ថា សារណាសេដ្ឋកិច្ចរបស់គាត់ធ្វើឲ្យគាត់សម្រេចចិត្តថា ប្រទេសកម្ពុជាត្រូវតែគ្រប់គ្រងវិស័យសេដ្ឋកិច្ចដោយខ្លួនឯង ដោយសារតែរចនាសម្ព័ន្ធខស្សរាហកម្មពីប្រទេសបារាំង កំពុងតែគ្រប់គ្រងសិប្បកម្មនិងជំនួញតូចៗរបស់ប្រទេសកម្ពុជាអស់ហើយ ។ ក្រោយមក ខៀវ សំផន បានពន្យល់ពីអ្វីដែលជាសេចក្តីសន្និដ្ឋានបានប៉ះពាល់ដល់សកម្មភាពរបស់គាត់ ពេលដែលគាត់ធ្វើជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទោះបីជាគាត់បានចាក់ចេញពីប្រទេសបារាំងយូរហើយក៏ដោយ ។

ទាក់ទងទៅការត្រឡប់មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ១៩៥៨ ខៀវ សំផន បានបញ្ជាក់ថា គាត់មិនមានទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តកម្ពុជាទេនៅពេលនោះ ។ គាត់បញ្ជាក់ថា «ជាការប្រថុយ

ប្រថានណាស់» ដែលគាត់ចង់ទាក់ទងជាមួយបក្សកុម្មុយនីស្តកម្ពុជានោះ ព្រោះគាត់ត្រូវបានតាមដានយ៉ាងជាប់ដោយរដ្ឋាភិបាលសម្តេច សីហនុ ។ តែក្រោយពីគាត់ត្រឡប់មកវិញ គាត់បានបើកកាសែត L’Observateur ដែលសរសេរជាភាសាបារាំង ។ គោលបំណងរបស់កាសែតនោះ គឺដើម្បីបំពេញតម្រូវការប្រជាធិបតេយ្យនិងការកែទម្រង់ដើម្បីតភ្ជាប់ចន្លោះប្រហោងរវាងអ្នកមាននិងអ្នកក្រ ។ ខៀវ សំផន បានអះអាងថា ពេលនោះមេដឹកនាំកម្ពុជាមិនចង់អានកាសែតខ្មែរទេ ។ ខៀវ សំផន បានបដិសេធអំពីការចោទប្រកាន់ទាំងឡាយថា កាសែតរបស់គាត់ទទួលបានមូលនិធិតែពីជនកុម្មុយនីស្តប៉ុណ្ណោះ ជាជាងទទួលបានមូលនិធីពីតំណាងនានា ។ ក្រោយមក ខៀវ សំផន បានអះអាងថា រដ្ឋាភិបាលបានចោទប្រកាន់កាសែតរបស់គាត់ថា មាននិន្នការ«ក្រហម»ទៅរកកុម្មុយនីស្ត ដែលជាមួយក្តីបារម្ភរបស់សម្តេច សីហនុ ។ ការខ្លាចនេះបណ្តាលឲ្យ ខៀវ សំផន ត្រូវបានសួរសំណួរដោយប៉ូលិស វាយដំ និងចាប់ស្រាតនៅទីសាធារណៈ ហើយបានឃុំឃាំងគាត់អស់រយៈពេលមួយខែដោយគ្មានការជំនុំជម្រះ ហើយទីបញ្ចប់កាសែតរបស់គាត់ត្រូវបានបង្ខំឲ្យបិទ ។

ត្រង់ចំណុចនេះ ចៅក្រម និល ណុន បាននិយាយកាត់ការអានរបស់ ខៀវ សំផន ហើយសម្រាកនៅពេលរសៀល ។

មុននឹង ខៀវ សំផន អានសេចក្តីថ្លែងការណ៍បន្តទៀត អាង ឧត្តម មេធាវីរបស់ អៀង សារី បានស្នើទៅតុលាការ ដើម្បីឲ្យកូនក្តីរបស់គាត់នៅតាមដានដំណើរការនៅបន្ទប់រង់ចាំវិញព្រោះខ្នងរបស់គាត់ឈឺ ។ ក្រោយពីចុះហត្ថលេខានៅលើក្រដាសរួចហើយ អៀង សារី ត្រូវបានរុញដោយកៅអីរុញទៅបន្ទប់រង់ចាំ ។ ក្រោយមក មេធាវី ខាណាវ៉ាស បានស្នើឲ្យតុលាការបង្វែរមាស៊ីនត្រជាក់ឡើងលើបន្តិចព្រោះ«គាត់មានអារម្មណ៍ថា គាត់ហាក់បីដូចជាកំពុងតែអង្គុយនៅរដ្ឋអាឡាស្កាអ៊ីចឹង» ។ សំណើនេះធ្វើឲ្យចៅក្រមបម្រុងងក់ក្បាល ដែលប្រហែលជាយល់ព្រមនឹងសំណើនោះដែរ ។

មន្ត្រីតុលាការទៅបង្វែម៉ាស៊ីនត្រជាក់ ហើយចៅក្រម និល ណុន បានជូនដំណឹងទៅគ្រប់ភាគីទាំងអស់ថា សវនាការនឹងឲ្យ ឡុង នរិន្ទ ធ្វើសក្ខីកម្ម បើសិនជាគាត់មានសុខភាពល្អ ។ បើសិនជាសាក្សីមិនអាចធ្វើសក្ខីកម្មបានទេ ជនជាប់ចោទ នួន ជា នឹងត្រូវកោះហៅមកសាកសួរបន្ត ។

ទីបញ្ចប់ ខៀវ សំផន មានឱកាសអានសេចក្តីថ្លែងការណ៍របស់គាត់បន្តដោយរៀបរាប់ពីពេលដែលគាត់ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតឲ្យធ្វើជាសមាជិករដ្ឋសភា ហើយក្រោយមកធ្វើជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ១៩៦២ ដោយ ខៀវ សំផន បញ្ជាក់ថា សម្តេច សីហនុ មានបំណង«ទិញទឹកចិត្តខ្ញុំ» ។ ខៀវ សំផន បានថ្លែងទៀតថា គាត់ចង់ធ្វើការដើម្បីប្រទេសដោយផ្តោតទៅលើគម្រោង ដើម្បីបង្កើតមូលដ្ឋានឯករាជ្យមួយសម្រាប់សេដ្ឋកិច្ចកម្ពុជា ។ សម្តេច

សីហនុ បានប្រឹក្សាជាមួយទីប្រឹក្សាជាន់ខ្ពស់របស់ព្រះអង្គជាពិសេស សម្តេច សឺន សាន ដែលជាទេសាភិបាលធនាគារជាតិនៅពេលនោះ ដើម្បីពិនិត្យមើលថាតើរដ្ឋាភិបាលគាំទ្រគម្រោងរបស់ ខៀវ សំផន ដើម្បីគ្រប់គ្រងពាណិជ្ជកម្មបរទេសដែរឬអត់ ។

ខៀវ សំផន និយាយថា សឺន សាន គាំទ្រគម្រោងរបស់គាត់ ហើយស្នើគាត់ឲ្យស្នើគម្រោងនោះទៅសម្តេច សឺន សាន ដើម្បីឲ្យសម្តេចយកគម្រោងនោះទៅទូលសម្តេច សីហនុ ។ ព្រះមហាក្សត្រមានការព្រួយបារម្ភនៅពេលនោះថា កម្ពុជាពឹងផ្អែកទៅលើជំនួយហិរញ្ញវត្ថុរបស់អាមេរិកដែល «ប្រៀបដូចជាកាំបិតភ្ជង់កកម្ពុជាដូច្នោះដែរ» ហើយព្រះអង្គព្រមទទួលយកគម្រោងរបស់ ខៀវ សំផន ។ មុននឹង ខៀវ សំផន អនុវត្តគម្រោងនោះ ខៀវ សំផន បានបាត់បង់អាសនៈនៅរដ្ឋសភា ។

ក្រោយមក ខៀវ សំផន បានពន្យល់ពីហេតុផលរបស់គាត់ ដែលបានរត់ចូលព្រៃក្នុងឆ្នាំ ១៩៦៧ ។ គាត់បានបញ្ជាក់ថា គាត់គ្មានជម្រើសអ្វីផ្សេងទេ តែត្រូវតែគេចខ្លួនដើម្បីសុវត្ថិភាពពីការគំរាមកំហែង ។ គាត់បានអះអាងបញ្ជាក់ថា កាលនោះគាត់ប្រឈមមុខនឹងការចាប់ខ្លួន ហើយតុលាការយោធាអះអាងថា គាត់បានញុះញង់កសិករតាមរយៈកាសែតរបស់គាត់ ។ តែ ខៀវ សំផន បដិសេធការចោទប្រកាន់បែបនេះ ព្រោះកសិករមិនអាចអានភាសាបារាំងបានទេ ហើយកាសែតរបស់គាត់បោះពុម្ពជាភាសាបារាំង ។ ខៀវ សំផន មានជំនឿថា គាត់ត្រូវបានកំណត់ទិសដៅក្នុងការចាប់ខ្លួនពីព្រោះ លន់ នល់ បានបញ្ចុះបញ្ចូលសម្តេច សីហនុ ឲ្យចាប់ពួកឆ្វេងនិយមដើម្បីផ្គាប់ចិត្តអាមេរិកកាំងដែលនៅគាំទ្រ លន់ នល់ និង«ដៃជើងរបស់គាត់» ។

ក្រោយពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ក្នុងឆ្នាំ១៩៧០ ខៀវ សំផន ត្រូវបាននាំចូលក្នុងផែនការរបស់ ប៉ុល ពត និងបក្សកុម្មុយនីស្តដោយមិនដឹងខ្លួននិងគ្មានការយល់ព្រមពីគាត់ទេ ។ ដូច ខៀវ សំផន ហើយនិងអ្នកផ្សេងទៀតដែរ រួមទាំង តាម៉ុក ដងលាក់ខ្លួននៅក្នុងព្រៃ ហើយ ប៉ុល ពត បានសរសេរសំបុត្រគាំទ្រដល់ចលនាបះបោរ ហើយបានចុះហត្ថលេខានៅលើសំបុត្រនោះដោយមានឈ្មោះរបស់ ខៀវ សំផន និងអ្នកផ្សេងទៀត ដោយអ្នកទាំងនោះមិនដឹងខ្លួនទេ ។ ក្រោយមក ប៉ុល ពត បានតែងតាំង ខៀវ សំផន ឲ្យកាន់តួនាទីជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងមេបញ្ជាការយោធារបស់រណសិរ្សប្រួបប្រួមជាតិកម្ពុជា ជាតំណែងដែល ខៀវ សំផន ទើបតែដឹងពេលដែលគាត់ឮការប្រកាសតាមវិទ្យុប៉ុណ្ណោះ ។

នៅក្នុងតួនាទីនេះ ខៀវ សំផន ត្រូវបានប្រគល់«ការងារជាស្ពាន»រវាងបក្សកុម្មុយនីស្តកម្ពុជានិងសម្តេច សីហនុ ដែលមានតួនាទីជាស្តេចតំណាងឲ្យវណ្ណៈសក្តិភូមិចាស់ ដើម្បីត្រួសត្រាយផ្លូវឲ្យមាន

ការឲ្យផ្ទុះផ្សាគ្នារវាងកម្លាំងទាំងអស់ដើម្បីរំដោះយកទីក្រុងភ្នំពេញ ។ ខៀវ សំផន បានចោទ សួរថា «តើតំណែងជាស្ពាននោះគឺជាបទឧក្រិដ្ឋដែរឬ? ពិតណាស់ មិនមែនទេ» ។

ខៀវ សំផន បានបញ្ជាក់ទៀតថា ទោះបីជាគាត់មានតំណែងទាំងអស់នោះក៏ដោយ តែគាត់គ្មានអំណាចពិតប្រាកដទេ ។ គាត់គឺជា «ឧបនាយករដ្ឋមន្ត្រីខ្យល់ នាយករដ្ឋមន្ត្រីការពារជាតិខ្យល់ មេបញ្ជាការខ្យល់» ។ ខៀវ សំផន បានបញ្ជាក់ទៀតថា គាត់មិនមានអំណាចអ្វីទេទោះបីជាគាត់មានឈ្មោះក្នុងតំណែងជាមេបញ្ជាការយោធាក៏ដោយ «ខ្ញុំមិនមានកងទាហានតូចបំផុតមួយក្រោមបញ្ជារបស់ខ្ញុំផង» ។ ទីបញ្ចប់ ខៀវ សំផន បានបញ្ជាក់ពីតួនាទីរបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ដោយបញ្ជាក់ថា គាត់ចូលជាសមាជិកបក្សក្នុងឆ្នាំ១៩៦៩ «ដោយសារសុវត្ថិភាពរបស់ខ្ញុំ» ខៀវ សំផន បានបញ្ជាក់ទៀតថា គាត់មិនមែនជាសមាជិកពេញសិទ្ធិទេ ព្រោះគាត់មិនបានបំពេញតម្រូវការរបស់បក្សដើម្បីចូលជាសមាជិកទេ ។ តាមពិត គាត់គឺជាបញ្ញាជន ហើយមិនមែនជាថ្នាក់កសិករក្រីក្រទេ ដូច្នេះគាត់មិនមាន«ឋានៈសង្គមស្អាតស្អំទេ» ។ ដូច្នេះគាត់មិនអាចចូលជាសមាជិកពេញសិទ្ធិរបស់បក្សបានទេ ។ ទោះបីជាគាត់ក្លាយជាសមាជិកមជ្ឈិមបក្សក្នុងឆ្នាំ១៩៧១ក៏ដោយ ក៏គាត់ត្រូវបានចាត់ឲ្យចូលក្នុងក្រុមឥស្សរៈជនឬជា«មនុស្សនាំមុខ» ព្រោះបក្សត្រូវការគាត់ជាអ្នកទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងសម្តេច សីហនុ ។ បក្សប្រគល់ជូនគាត់តែតំណែងប៉ុណ្ណោះ តែមិនប្រគល់អំណាចទេ ។

ខៀវ សំផន បញ្ជាក់ទៀតថា គាត់មិនអាចធ្វើការសម្រេចចិត្តបានទេ ។ គាត់បានសន្និដ្ឋានថា «បក្សកុម្មុយនីស្តកម្ពុជាមើលឃើញខ្ញុំថាជាបញ្ញាវន្ត ហើយមិនមែនជាសមាជិកបក្សទេ ។ នេះគឺពិតទាំងស្រុង ។ រហូតដល់ឆ្នាំ១៩៧៥ ស្ថានភាពរបស់ខ្ញុំនៅតែដដែល» ។ ទីបញ្ចប់ ចៅក្រម និល ណុន បានថ្លែងអំណរគុណដល់ ខៀវ សំផន ដែលបានអានសេចក្តីថ្លែងការណ៍ «យ៉ាងក្បោះក្បាយ» ហើយគាត់បញ្ជាក់ប្រាប់គ្រប់ភាគីទាំងអស់ថា សវនាការអាចបន្តដំណើការរហូតដល់ព្រឹកថ្ងៃសុក្រ ទៀតក្នុងសប្តាហ៍នេះ ។ សវនាការថ្ងៃនេះបញ្ចប់ ។ ថ្ងៃស្អែកនឹងមានការធ្វើសក្ខីកម្មរបស់សាក្សី ឡុង នរិន្ទ ។

**-ចប់-**